# ការចូលរួមជាសាធារណៈនៅក្នុងការប្រជុំក្រុមប្រឹក្សាភិបាលនៃការអប់រំ

វាត្រូវបានរំពឹងទុកថាសមាជិកក្រុមប្រឹក្សាភិបាលក្រសួងអប់រំ នឹងមានវត្តមាននៅក្នុងការប្រជុំ ក៏ប៉ុន្តែ អនុលោមតាមបទបញ្ជាប្រតិបត្តិរបស់ចៅហ្វាយខេត្ត ហ្គាវិន នូសំ លេខ N-25-20(11) ហើយដែលបានកែឡើងវិញដោយបទបញ្ជាប្រតិបត្តិ N-29-20 សមាជិកក្រុមប្រឹក្សាភិបាលអាចចូលរួមប្រជុំនិង ធ្វើការបោះឆ្នោតពីចម្ងាយតាមរយៈទូរសន្និសិទ បើសិនជាពួកគាត់សម្រេចធ្វើដូច្នោះ។ សមាជិកនៃសាធារណៈជនអាចទស្សនាការប្រជុំដែលផ្សាយផ្ទាល់ស្របពេលគ្នានៅ lbschools.net/youtube

ដើម្បីគោរពធ្វើតាមការបញ្ជារបស់រដ្ឋនិងក្រុង ស្តីអំពីការជួបប្រមូលផ្តុំគ្នាជាសាធារណៈ សមាជិកសាធារណៈជនពុំអាចមកចូលរួមក្នុងការប្រជុំក្រុមប្រឹក្សាភិបាលដោយផ្ទាល់បានឡើយ លើកលែងតែដូចតាមការព៌ណនាខាងក្រោមនេះ-

ក្រុមប្រឹក្សាភិបាលការអប់រំឱ្យតម្លៃលើមតិរបស់សាធារណៈជនហើយលើកទឹកចិត្តឱ្យសមាជិកសាធារណៈជនផ្តល់មតិជា សាធារណៈនៅក្នុងការប្រជុំ។ សមាជិកសាធារណៈជនណាម្នាក់ដែលចង់និយាយបញ្ចេញយោបល់ដល់ក្រុមប្រឹក្សាភិបាល អាចចូលមកក្នុងសាលប្រជុំម្នាក់ម្តងហើយដើរសំដៅឆ្ពោះទៅកាន់មីក្រូហ្វូន នៅពេលគេហៅឈ្មោះគាត់។ រាល់សមាជិកនៃសាធារណៈជន លើកលែងតែបុគ្គលណាដែលត្រូវបានលើកលែងដោយច្បាប់ ត្រូវតែពាក់ម៉ាសជាក្រណាត់គ្របច្រមុះនិងមាត់ ហើយត្រូវតែចាកចេញពីសាលប្រជុំភ្លាមបន្ទាប់ពីបានបញ្ចប់ពេលវេលារបស់គាត់ ដើម្បីអនុញ្ញាតឱ្យបុគ្គលបន្ទាប់មកទៀតចូលមកនិយាយបញ្ចេញមតិ។ វត្តមាននៅក្នុងការប្រជុំនឹងត្រូវមានកំណត់ឱ្យត្រឹមតែបុគ្គលិកចាំបាច់(ដែលគាត់ត្រូវការពាក់ម៉ាសដែរ) ហើយនិងសមាជិកសាធារណៈជនដែលឱ្យចូលម្តងមួយៗ នៅក្នុងពេលសម្រាប់ឱ្យបញ្ចេញមតិសាធារណៈ។ សាលប្រជុំនឹងត្រូវរៀបចំឱ្យដាក់គម្លាតពីគ្នា ឱ្យមានចំងាយយ៉ាងតិចប្រវែង៦ហ្វីតពីគ្នា ជានិច្ចជាកាល។